ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

សំណុំរឿងព្រហ្មទណ្ឌលេខ ១៧០៥ អ.ក
ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០
សាលក្រមលេខ ០៣៦ ស.ព្រ.ណ/២១
ចុះថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ២០២១

# តាងនាមប្រជារាស្ត្រខ្មែរ

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តកណ្ដាល ។
កាលបរិច្ឆេទសវនាការ ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ ។
កាលបរិច្ឆេទនៃការប្រកាសសាលក្រមថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១ ។

## ចៅក្រមជំនុំជម្រះ

លោក [redacted] ចៅក្រមជំនុំជម្រះ

## តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារង

## ក្រឡាបញ្ជី

លោក [redacted] ក្រឡាបញ្ជីសវនាការ

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ ១៧០៥ អ.ក ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១ ដែលមានជនជាប់ចោទឈ្មោះ [redacted] ស្មី ភេទស្រី អាយុ ២៧ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរមេផ្ទះ ទីកន្លែងកំណើតនៅសង្កាត់ [redacted] ខេត្តព្រះសីហនុ និង ទីលំនៅបច្ចុប្បន្ននៅភូ [redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] គុជ (រស់) ម្ដាយឈ្មោះ [redacted] គីមចេត (រស់) ប្ដីឈ្មោះ [redacted] ស្មី មានកូន ០២នាក់ ជានីតិជន ទោសពីមុខគ្មាន ។ (ក្រៅឃុំ)

ត្រូវបានជាប់ចោទពី បទហិង្សាដោយចេតនា ប្រព្រឹត្តនៅភូមិថ្មី សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២០ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្ដន្ទាទោសស្របតាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។

ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុក ភេទស្រី អាយុ ៣៣ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិអរអង្គ ឃុំសារគ្រាម ស្រុកប្រាសាទបាល័ង្គ ខេត្តកំពង់ធំ ( ត្រូវជាម្ដាយជនរងគ្រោះឈ្មោះ [redacted] សុរីន ភេទស្រី អាយុ ១៧ឆ្នាំ ) ។ (បានដកពាក្យបណ្ដឹង)

មានមេធាវី [redacted] , មេធាវី [redacted] និងមេធាវី [redacted] ការពារសិទ្ធិឱ្យដើមបណ្ដឹងរដ្ឋប្បវេណី ។



Scanned with CamScanner

មានលោកមេធាវី [redacted] និងមានលោកស្រីមេធាវី [redacted] ការពារសិទ្ធិឱ្យឈ្មោះជនជាប់ចោទ ។

- **បានឃើញ** ដីកាដំណោះស្រាយលេខ ១៩៣០ ដកដស(ន)/២០ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០ ។

## អង្គហេតុដែលបានចោទប្រកាន់បញ្ជូនមកជំនុំជម្រះ

កាលពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៩ មានជនរងគ្រោះឈ្មោះ [redacted] **សុរីន** បានចូលរួមបម្រើការងារក្នុងផ្ទះរបស់ជនជាប់ចោទឈ្មោះ [redacted] **រស្មី** ហៅរស្មី ដែលស្ថិតនៅភូមិថ្មី សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល ក្នុងឋានៈជាឈ្នួល ដើម្បីធ្វើការងារផ្ទះដោយឱ្យប្រាក់ខែចំនួន ១០០ ដុល្លារអាមេរិចក្នុង ០១ (មួយ)ខែ។ ចាប់តាំងពីចូលធ្វើការមក ជនជាប់ចោទតែងតែប្រើអំពើហិង្សាទៅលើជនរងគ្រោះ ដោយបានយលដែកសម្ល កាបិត គប់ និង វាយលើជនរងគ្រោះជាញឹកញាប់ បណ្ដាលឱ្យជនរងគ្រោះមានស្នាមរបួសរយៈហូរឈាមជាច្រើនកន្លែង ក្រោយមកជនរងគ្រោះក៏បានរត់ចេញពីផ្ទះ និង បានទៅដាក់ពាក្យនៅសមត្ថកិច្ចតែម្តង។

## ដំណើរការនៃកិច្ចពិភាក្សាដេញដោល

១. អំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **រស្មី** ៖ នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៩ ដោយខ្ញុំបានប្រើឱ្យឈ្មោះ [redacted] ស៊ីរីន អាំងត្រី តែឈ្មោះនេះមិនបានមើលភ្លើងធ្វើហើយត្រីឆៅ ពេលនោះខ្ញុំក៏បានស្ដីបន្ទោស និង បានយកដៃរុញស្មាទៅលើឈ្មោះ [redacted] **ស៊ីរីន** ហើយខ្ញុំក៏បានប្រើឈ្មោះនេះឱ្យទៅទិញទឹកត្រីមួយដប ស្រាប់តែឈ្មោះនេះទៅបាត់រហូត និង មិនបានត្រឡប់មកវិញទេ បន្ទាប់មកខ្ញុំក៏បានទៅរាយការណ៍ប្រាប់សមត្ថកិច្ច អធិការដ្ឋានក្រុងតាខ្មៅ ។

២. អំណានចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] **ស៊ីរីន** ៖ ខ្ញុំបានទៅធ្វើការបម្រើតាមផ្ទះរបស់ឈ្មោះ [redacted] **រស្មី** រយៈពេលជិត៣ឆ្នាំហើយ ដោយខ្ញុំធ្វើការបោសផ្ទះ ដាំបាយ លាងចាន និង ហាលខោអាវ លុះដល់ថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង១១ព្រឹក ឈ្មោះ [redacted] **រស្មី** បានប្រើខ្ញុំឱ្យអាំងត្រី ដោយខ្ញុំដាក់រងើកតិចពេកខ្លាចខ្លោច ពេលនោះឈ្មោះ [redacted] **រស្មី** ចុះមកឃើញក៏បានជេរខ្ញុំថាខ្ញុំល្ងង់ម្លេះដាក់រងើកតិចពេក ក៏បានយកដែកសម្លមកវាយខ្លួនចំនួន ០២ ដែកចំថ្គាមទាំងសងខាង រយៈពេល៤ខែដែលខ្ញុំធ្វើការនឹងឈ្មោះ[redacted] **រស្មី** ឈ្មោះនេះតែងតែប្រើអំពើហិង្សាលើខ្ញុំ ថែមទាំងគម្រាមសម្លាប់ខ្ញុំថែមទៀត ទើបខ្ញុំទ្រាំមិនបានទើបសម្រេចចិត្តរត់ចេញពីផ្ទះតែម្តង ។

៣. អំណាចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុក ខ្ញុំជាម្ដាយរបស់ជនរងគ្រោះឈ្មោះ [redacted] **ស៊ីរីន** បានតាំងខ្លួនជាដើមបណ្ដឹងប្ដឹងទាមទារសំណងជំងឺចិត្តថ្លៃព្យាបាលរបួសឱ្យជនរងគ្រោះឈ្មោះ [redacted] **ស៊ីរីន** ចំនួន ៤០.០០០.០០០រៀល និង ទាមទារប្រាក់ខែដែលមិនបានបើកឱ្យកូនខ្ញុំ ។ ខ្ញុំយល់ព្រមដកពាក្យបណ្ដឹងលើឈ្មោះ [redacted] **រស្មី** ដោយហេតុថាគ្រួសារជនជាប់ចោទ បានសងជំងឺចិត្តថ្លៃព្យាបាលរបួស និងប្រាក់ខែ រួចរាល់ហើយ ។

៤. តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានប្ដឹងសុំថា ៖ នៅតែរក្សាការចោទប្រកាន់ និង ប្ដឹងសុំឱ្យតុលាការសម្រេចផ្ដន្ទាទោសជនជាប់ចោទ ដោយសំអាងថាមានភស្ដុតាងស៊ីសង្វាក់គ្នា ។

៥. មេធាវីការពារសិទ្ធិឱ្យជនជាប់បានធ្វើសេចក្ដីសន្និដ្ឋានថា ៖ សូមធ្វើសេចក្ដីសន្និដ្ឋានដូចមាននៅសេចក្ដីសន្និដ្ឋានការពារចុះថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ២០២១ ។

- ក្រោយពីបានស្ដាប់អំណានចម្លើយជនជាប់ចោទ
- ក្រោយពីបានស្ដាប់អំណានចម្លើយរបស់ដើមបណ្ដឹង
- ក្រោយពីបានស្ដាប់អំណានចម្លើយរបស់ជនរងគ្រោះ
- ក្រោយពីបានស្ដាប់ស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវី ជនជាប់ចោទ
- ក្រោយពីបានពិនិត្យភស្ដុតាងលើសំណុំរឿងនេះ

## សំអាងហេតុ

១. យោងតាមអំណានចម្លើយសារភាពរបស់ជនជាប់ចោទនៅពេលពិភាក្សាដេញដោល និង យោងតាមកំណត់ហេតុស្ដាប់ចម្លើយដើមបណ្ដឹង , ចម្លើយជនរងគ្រោះ និង ចម្លើយរបស់សាក្សី ព្រមទាំងភស្ដុតាងនានាអាចបញ្ជាក់បានថា ជនជាប់ចោទឈ្មោះ [redacted] រស្មី ពិតជាបានប្រើហិង្សាលើឈ្មោះ [redacted] ស៊ីរីន ដែលត្រូវជាឈ្នួលក្នុងផ្ទះដោយអោយប្រាក់ខែ ក្នុង០១ខែ ១០០ដុល្លារ ដែលស្ថិតក្នុងភូមិថ្មី សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល ចាប់តាំងពីចូលធ្វើការមកឈ្មោះ [redacted] រស្មី តែងតែធ្វើសកម្មភាពវាយលើឈ្មោះ [redacted] រស្មី បណ្ដាលឱ្យឈ្មោះនេះមាន របួសស្នាម និងបានរត់ចេញពីផ្ទះ ។ ដូចនេះតុលាការយល់ឃើញថាឈ្មោះ [redacted] រស្មី ពិតជាបានប្រើអំពើហិង្សាដោយចេតនា ដោយមានភស្ដុតាងស៊ីសង្វាក់គ្នា ។

២. ជនជាប់ចោទខាងលើ ជានីតិជន និង មានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ ។

៣. ជនត្រូវចោទខាងលើបានដឹងថា អំពើរបស់ខ្លួនជាអំពើផ្ទុយច្បាប់ ប៉ុន្តែនៅតែប្រព្រឹត្តផ្ទុយច្បាប់ទៀត ។ ដូចនេះតុលាការយល់ឃើញថា ជនត្រូវចោទមានចេតនាក្នុងការប្រព្រឹត្តបទល្មើស ។

៤. តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា សុំរក្សាការចោទប្រកាន់លើជនជាប់ចោទដដែល និងប្ដឹងសុំឱ្យតុលាការផ្ដន្ទាទោសជនជាប់ចោទ ដោយតាមភស្ដុតាងមានភាពស៊ីសង្វាក់គ្នា ។ តុលាការឯកភាពស្របតាមការប្ដឹងសុំនេះ ព្រោះជនជាប់ចោទ ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ពិតមែន ហើយតុលាការនឹងពិចារណាសម្រេចស្របទៅតាមអង្គហេតុ និង អង្គច្បាប់ ។

៥. បន្ទាប់ពីឆ្លងកាត់ការពិភាក្សាដេញដោល និង ការពិនិត្យនូវភស្ដុតាងនានាក្នុងសំណុំរឿង អាចបញ្ជាក់បានថា ជនជាប់ចោទឈ្មោះ [redacted] រស្មី បានប្រព្រឹត្ត **បទហិង្សាដោយចេតនា** ប្រព្រឹត្តនៅភូមិថ្មី សង្កាត់ខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២០ ជាបទល្មើស



Scanned with CamScanner

ព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសស្របតាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។

## ហេតុដូច្នេះសម្រេច

១. ផ្តន្ទាទោសជនជាប់ចោទ ឈ្មោះ [redacted]វស្នី ភេទស្រី អាយុ ២៧ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០១ ឆ្នាំ ដោយត្រូវអនុវត្តទោស ដាក់ពន្ធនាគារកំណត់រយៈពេល ០១ខែ ០៧ថ្ងៃ ទោសនៅសល់ព្យួរ ធម្មតា ពី **បទហិង្សាដោយចេតនា** ប្រព្រឹត្តនៅភូមិថ្មីសង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២០ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសស្របតាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។

២. រឹបអូសវត្ថុតាង វែកសម្លរចំនួន ០១ កាំបិតប៉ុងតោចំនួន ០១ ដងជូតឥដ្ឋការ៉ូ ចំនួន ០១ អាវយឺតដៃវែង ពណ៌ប្រផេះ ចំនួន ០១ ។

សាលក្រមនេះ ចាត់ទុកចំពោះមុខជនជាប់ចោទ ។ បើកសិទ្ធិប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍ តាមនីតិវិធីច្បាប់។

ថ្ងៃច័ន្ទ ១១កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
កណ្តាល, ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១

**ក្រឡាបញ្ជី**
ហត្ថលេខា និង ត្រា [redacted]

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និង ត្រា [redacted]

---

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃច័ន្ទ ១១កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស២៥៦៤
កណ្តាល, ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១

បានឃើញ
**ចៅក្រមជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជី**

[redacted]